**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**

**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ បព ១៥/២០២៥ កបទ.សអ

**សេចក្តីប្រកាសព័ត៌មាន**

**កម្ពុជាថ្កោលទោសយ៉ាងខ្លាំងក្លាចំពោះការឈ្លានពានរបស់ថៃលើអធិបតេយ្យកម្ពុជា**

ឆ្លើយតបនឹងសំណើរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៥ ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSC) បានធ្វើការកោះប្រជុំចង្អៀតជាបន្ទាន់មួយ ដើម្បីពិភាក្សាអំពីជម្លោះព្រំដែនដ៏តានតឹងរវាងកម្ពុជា និងថៃ។ ឯកឧត្តម កែវ ឈា ឯកអគ្គរាជទូត និងជាតំណាងចិរន្តរ៍របស់ព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ បានចូលរួមធ្វើសេចក្តីថ្លែងការណ៍នៅក្នុងកិច្ចប្រជុំនេះ ដោយបានទាញចំណាប់អារម្មណ៍របស់ក្រុមប្រឹក្សាសន្តិសុខទៅលើការបើកប្រតិបត្តិការឈ្លានពានប្រដាប់អាវុធទ្រង់ទ្រាយធំរបស់ប្រទេសថៃមកលើអធិបតេយ្យ និងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា កាលពីព្រឹកថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២៥។

ឯកឧត្តមឯកអគ្គរាជទូតបានរាយការណ៍ជូនក្រុមប្រឹក្សាសន្តិសុខ អំពីការវាយប្រហាររបស់កងទ័ពថៃដែលមានការគិតទុកមុន ក្នុងចេតនាបង្កហេតុ មកលើតំបន់ព្រំដែនរបស់កម្ពុជា រួមមានប្រាសាទតាមាន់ធំ ប្រាសាទតាក្របី និងតំបន់មុំបី ក្នុងខេត្តព្រះវិហារ និងឧត្តរមានជ័យ។ ឯកឧត្តមឯកអគ្គរាជទូត បានថ្កោលទោសយ៉ាងខ្លាំងក្លាចំពោះការឈ្លានពាននេះ ដែលបានរំលោភបំពានយ៉ាងគឃ្លើនលើគោលការណ៍ជាមូលដ្ឋានស្តីពីការមិនឈ្លានពានគ្នា និងការដោះស្រាយវិវាទដោយសន្តិវិធី ដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។

ឯកឧត្តមឯកអគ្គរាជទូត បានបង្ហាញអំពីការរៀបចំ និងគិតទុកមុន នៃការវាយប្រហារពីសំណាក់យោធាថៃមកលើទីតាំងជាច្រើនកន្លែងរបស់កម្ពុជា ដោយប្រើអាវុធធុនធ្ងន់ រួមមានយន្តហោះចម្បាំង F-16 រថក្រោះ និងគ្រាប់បែកចង្កោម។ ជាមួយគ្នានេះ ថៃក៏បានពង្រីកការត្រៀមបើកប្រតិបត្តិការយោធាដល់ខេត្តច័ន្ទបុរី និងខេត្តត្រាតផងដែរ ខណៈដែលភាគីកម្ពុជាពុំមានការចល័តទ័ពទៅតំបន់ជាប់ព្រំដែនខេត្តទាំងពីរនេះសោះ។ ការឈ្លានពានទ្រង់ទ្រាយធំដោយយោធាថៃ ដែលផ្ទុយទាំងស្រុងពីការលើកឡើងរបស់ថៃថា

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

ជាការការពារខ្លួននោះ បានធ្វើឱ្យជនស៊ីវិលបាត់បង់ជីវិតចំនួន៨នាក់ រងរបួស ៥០នាក់ និង១០.៨៦៥ គ្រួសារត្រូវជម្លៀសចេញពីតំបន់គ្រោះថ្នាក់ ក្នុងខេត្តឧត្តរមានជ័យ ព្រះវិហារ និងបន្ទាយមានជ័យ។ លើសពីនេះ ការវាយប្រហារដោយមិនរើសមុខរបស់ថៃមកលើកម្ពុជា បានបង្កនូវការខូចខាតយ៉ាងដំណំមកលើប្រាសាទព្រះវិហារ។ ការបំផ្លិចបំផ្លាញដោយចេតនាចំពោះតំបន់បេតិកភណ្ឌពិភពលោករបស់អង្គការយូនីស្កូនេះ គឺជាការរំលោភបំពានលើអនុសញ្ញាទីក្រុងឡាអេ ឆ្នាំ១៩៥៤។

ឯកឧត្តមឯកអគ្គរាជទូតបានស្នើសុំក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិធ្វើយ៉ាងណាឱ្យមានបទឈប់បាញ់មួយជាបន្ទាន់ និងដោយគ្មានលក្ខខណ្ឌ ដើម្បីបញ្ឈប់ការឈ្លានពានប្រដាប់អាវុធដោយគ្មានការបង្កហេតុជាមុនមកលើកម្ពុជា គាំទ្រដល់កិច្ចខិតខំប្រឹងប្រែងប្រកបដោយសន្តិវិធីរបស់កម្ពុជា និងស្នើឱ្យប្រទេសថៃគោរពច្បាប់អន្តរជាតិ និងកាតព្វកិច្ចសន្ធិសញ្ញារបស់ខ្លួន។ ឯកឧត្តមឯកអគ្គរាជទូត ក៏បានស្នើឱ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បញ្ជូនបេសកកម្មស្វែងយល់ការពិតនៅតំបន់ព្រំដែន ដែលរងការឈ្លានពាន និងបញ្ជូនបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃទៅតុលាការយុត្តិធម៌អន្តរជាតិដើម្បីធ្វើការវិនិច្ឆ័យ។

សមាជិកនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានសម្តែងនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះកំណើនភាពតានតឹងនៅតាមព្រំដែនកម្ពុជា-ថៃនាពេលថ្មីៗនេះ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រជាជនក្នុងតំបន់ និងបណ្តាលឱ្យមានជនស៊ីវិលស្លាប់បាត់បង់ជីវិត។ សមាជិកនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិបានអំពាវនាវឱ្យមានការអត់ធ្មត់ជាអតិបរមា និងឱ្យមានបទឈប់បាញ់ជាបន្ទាន់ និងដោយឥតលក្ខខណ្ឌ សំដៅទប់ស្កាត់កំណើនអរិភាព ព្រមទាំងបង្កើតលំហសម្រាប់កិច្ចសន្ទនាដោយសន្តិវិធី និងដំណោះស្រាយការទូត ក្នុងស្មារតីភាពជាអ្នកជិតខាងល្អ និងក្នុងបំណងស្វែងរកដំណោះស្រាយចំពោះជម្លោះនេះ។

ទន្ទឹមនឹងនេះ សមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ បានលើកទឹកចិត្តភាគីទាំងពីរឱ្យប្រើប្រាស់បានពេញលេញនូវការសម្រុះសម្រួលដោយសន្តិវិធីរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ព្រមទាំងគាំទ្រតួនាទីរបស់អាស៊ាន។ សមាជិកក្រុមប្រឹក្សាសន្តិសុខមួយចំនួន ក៏បានកត់សម្គាល់ពីបំណងរបស់កម្ពុជា ក្នុងការបញ្ជូនតំបន់ជម្លោះព្រំដែនចំនួនបួន គឺប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ទៅតុលាការយុត្តិធម៌អន្តរជាតិ សម្រាប់ធ្វើការវិនិច្ឆ័យ៕

*សូមផ្ជូនភ្ជាប់សេចក្តីថ្លែងការណ៍ទាំងស្រុងរបស់ឯកឧត្តមឯកអគ្គរាជទូត កែវ ឈា ។*

ថ្ងៃសៅរ៍ ១កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៥

KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 15/2025 MFA.IC

PRESS RELEASE

# Cambodia Strongly Condemns Thailand's Aggression against Cambodia's Sovereignty

On 25 July 2025, in response to the request of **Samdech Moha Borvor Thipadei Hun Manet,** Prime Minister of the Kingdom of Cambodia, the United Nations Security Council ( UNSC ) convened an urgent private meeting to address the escalating conflict between Cambodia and Thailand. Ambassador Keo Chhea, Permanent Representative of the Kingdom of Cambodia to the United Nations, participated in the meeting and delivered a national statement drawing the Council's attention to the launch of a full-scale armed aggression by Thailand against the sovereignty and territorial integrity of the Kingdom of Cambodia, in the early hours of 24 July 2025.

Ambassador Keo Chhea apprised the Council of Thailand's deliberate, premeditated, and unprovoked military assault on Cambodian border areas, including Tamone Thom Temple, Ta Krabey Temple, and Mom Bei, in the provinces of Preah Vihear and Oddar Meanchey. He strongly condemned this military aggression, which flagrantly violated the fundamental principles of non-aggression and peaceful resolution of disputes enshrined in the Charter of the United Nations and the ASEAN Charter.

Ambassador Keo Chhea elaborated on the coordinated and premediated nature of the military offensives by Thailand on multiple Cambodian positions using heavy weaponry, including F-16 fighter jets, tanks and cluster munitions. At the same time, Thailand has also expanded its military operation preparedness to Chanthaburi and Trat provinces, despite no military movement in the adjacent border areas on the Cambodian side. This full-scale military aggression by Thailand, which is in no way for self-defence as falsely claimed by Thailand, has left 8 civilians dead and 50 injured, and more than 10.865 families evacuated from the danger zones in the provinces of Oddar Meanchey, Preah Vihear and Banteay Meanchey. Moreover, Thailand's indiscriminate assaults on Cambodia have caused significant damages to the Temple of Preah Vihear. The deliberate destruction of this UNESCO World Heritage Site is a violation of the Hague Convention of 1954.

Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

The Ambassador urged the Council to engender an immediate and unconditional ceasefire, to stop this unprovoked and armed aggression against Cambodia, to support Cambodia's peaceful efforts and to encourage Thailand to honor international law and its treaty obligations. He also requested the Council to dispatch a United Nations fact-finding mission to the affected border areas and refer the Cambodia-Thailand border dispute to the International Court of Justice ( ICJ ) for adjudication.

The Members of the UNSC expressed deep concern over the recent escalation along the Cambodia-Thailand border, which adversely affected the local population and resulted in civilian casualties. They appealed for maximum restraint and immediate ceasefire to prevent further hostilities and create space for peaceful dialogue and diplomatic solution in the spirit of good neighborliness with a view to finding solutions to the disputes.

Meanwhile, the UNSC Members encouraged both parties to make full use of the UN Secretary-General's good offices and supported ASEAN's role. Some members also took note of Cambodia's intent to refer to the ICJ for adjudication the four disputed border areas of Tamone Thom Temple, Tamone Touch Temple, Ta Krabey Temple and Mom Bei.

*Full statement of Ambassador Keo Chhea is herewith attached*.

Phnom Penh, 26 July 2025